**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- កម្ពុជា គឺជាទីកន្លែងដ៏ល្អបំផុតមួយ សម្រាប់ដំណើរទេសចរណ៍ ក្នុងរយៈពេល១០ឆ្នាំខាងមុខ
- ឆ្នាំ២០២១ កម្ពុជាប្រមូលចំណូលពីពន្ធដារ និងពន្ធគយបានជាង ៤ ៥០០លានដុល្លារ
- សេដ្ឋកិច្ចកម្ពុជាអាចកើនឡើង ៥% នៅឆ្នាំ ២០២២
- កម្ពុជានាំចេញអង្ករបានជាង ៦១០ ០០០តោន ក្នុងឆ្នាំ២០២១
- ទឹកត្រីកំពត ក្លាយជាផលិតផលសម្គាល់ភូមិសាស្ត្រ
- (GDP)សិង្ហបុរី ឆ្នាំ២០២១ បានកើនឡើងលឿនបំផុត គិតក្នុងរយៈពេលជាងមួយទសវត្សន៍កន្លងមក
- គម្រោងវិនិយោគសាធារណៈវៀតណាម ទៅលើការដឹកជញ្ជូនផ្តោតសំខាន់លើការ ដឹកជញ្ជូនតាមផ្លូវសមុទ្រ
- ពាណិជ្ជកម្មថៃ សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២១ (គិតជាពាន់លានបាត)
- អង្គការ OPEC+ ត្រូវបានរំពឹងថានឹងរក្សាការបង្កើនទិន្នផលប្រេងដែលបានគ្រោងទុក ខណៈមានការកើនឡើងនៃករណីឆ្លងវីរុសកូវីដ-១៩ បំប្លែងខ្លួនថ្មីអូមីក្រុង
- កំណើនសេដ្ឋកិច្ចរបស់បារាំង ឆ្នាំ២០២១ ខ្ពស់ជាងការព្យាករណ៍


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី២ ខែមករា ឆ្នាំ២០២២ លេខ ៖ ១០១

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កម្ពុជា គឺជាទីកន្លែងដ៏ល្អបំផុតមួយ សម្រាប់ដំណើរទេសចរណ៍ ក្នុងរយៈពេល១០ឆ្នាំខាងមុខ



ព្រះរាជាណាចក្រកម្ពុជា បានជាប់ចំណាត់ថ្នាក់ជាទីកន្លែងដ៏ល្អបំផុតមួយនៅក្នុងចំណោមទីកន្លែងដ៏ល្អផ្តាច់គេទាំង១០ សម្រាប់ដំណើរទេសចរណ៍ ក្នុងរយៈពេល១០ឆ្នាំខាងមុខនេះ។ ចំពោះទីកន្លែងដ៏ល្អផ្តាច់គេចំនួន៩ទៀតនោះគឺ ទីក្រុង Bend នៃសហរដ្ឋអាមេរិក ទីក្រុង Cashel នៃប្រទេសអៀរឡង់ ប្រទេសកូស្តារីកា កោះ Galápagos នៃប្រទេសអេក្វាឌ័រ កោះ Grenada នៃដែនសមុទ្រការ៉ាប៉ៀន ប្រទេសម៉ិកស៊ិកូ តំបន់ Patagonia នៃដែនគ្រប់គ្រងដោយប្រទេសអាហ្សង់ទីន និងឈីលី ប្រទេសព័រតូរីកូ និងតំបន់ប្រវត្តិសាស្ត្រ Transylvania នៃប្រទេសរ៉ូម៉ានី។ ប្រាសាទអង្គរវត្តរបស់កម្ពុជាយើង ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូផងដែរនោះ ត្រូវបានជាប់ចំណាត់ថ្នាក់ជាប្រាសាទដ៏ល្បីល្បាញបំផុតនៅក្នុងទ្វីបអាស៊ី។ ប្រាសាទអង្គរវត្ត គឺជាប្រាសាទដ៏ធំសម្បើមមួយនៃរមណីយដ្ឋានអង្គរ ដែលសាងសង់ឡើងក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ នៅដើមសតវត្សទី១២។ ទស្សនាវដ្តី Forbes បានបញ្ជាក់ថា ៖ "ប្រទេសកម្ពុជាបានចាប់ផ្តើមបើកដំណើរការប្រទេសរបស់ខ្លួនឡើងវិញ កាលពីខែវិច្ឆិកាកន្លងទៅនេះ ហើយការមកទស្សនាប្រាសាទអង្គរវត្តដ៏ល្បីល្បាញ ដែលមិនមានមនុស្សច្រើនកកកុញ គឺជារឿងដ៏អស្ចារ្យមួយ"។ *ដោយ ម៉ែន ខែមវរៈ ប្រភព ៖ AKP ចេញផ្សាយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។*

### ឆ្នាំ២០២១ កម្ពុជាប្រមូលចំណូលពីពន្ធដារ និងពន្ធគយបានជាង ៤ ៥០០លានដុល្លារ



*ដោយ ៖ thmeythmey*

កម្ពុជារកចំណូលបានពីពន្ធដារ និងពន្ធគយ សរុប ៤ ៥៣៧ លានដុល្លារ នៅក្នុងឆ្នាំ២០២១។ ប្រមុខរដ្ឋាភិបាល បានបញ្ជាក់ថា៖«ទោះបីកម្ពុជាស្ថិតក្នុងវិបត្តិកូវីដ-១៩ ក៏អគ្គនាយកដ្ឋានគយ និងអគ្គនាយកដ្ឋានពន្ធដារ អាចប្រមូលចំណូលបានល្អ ពិសេសនៅឆ្នាំ២០២១ នៅពេលរាជរដ្ឋាភិបាល បើកប្រទេសបានពេញលេញឡើងវិញ»។ កន្លងមកនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ប្រមូលចំណូលបានចំនួន ២ ២៩៤លានដុល្លារ ដែលស្មើនឹង៩៧,១%នៃផែនការ ខណៈអគ្គនាយកដ្ឋានពន្ធដារ ប្រមូលចំណូលពន្ធបាន ២ ២៤៣លានដុល្លារ លើសផែនការ២៤,០២% នៃច្បាប់គ្រប់គ្រង

ហិរញ្ញប្រចាំឆ្នាំ។

ចំណូលពន្ធគ្រប់ប្រភេទ ដែលកម្ពុជាប្រមូលនេះ គឺមានភាពល្អប្រសើរ នាចុងឆ្នាំ២០២១។ នេះ បង្ហាញនូវសញ្ញាវិជ្ជមាន ក្នុងការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ thmeythmey ចេញផ្សាយថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២។*

## សេដ្ឋកិច្ចកម្ពុជាអាចកើនឡើង ៥% នៅឆ្នាំ ២០២២



*ប្រភព៖ Hong Menea, Phnom Penh Post ២០២២*

ធនាគារកណ្តាល ដាក់កំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅត្រឹម ៥%សម្រាប់ឆ្នាំ២០២២ ដោយសារតែការរំពឹងទុកនៃការងើបឡើងវិញជាសកល ទោះបីជាមានការលេចឡើងនៃមេរោគបំប្លែងថ្មីក៏ដោយ យោងតាមធ្វើការព្យាករណ៍អំពី "ការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ច និងធនាគារនៅឆ្នាំ២០២១និងទស្សនវិស័យសម្រាប់ឆ្នាំ២០២២" ។

សេដ្ឋកិច្ចកម្ពុជា បានកើនឡើងប្រហែល៣% ក្នុងឆ្នាំ ២០២១ ដែលគាំទ្រដោយការបន្តសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងអត្ថប្រយោជន៍ជាច្រើន ដែលទទួលបានពីសេដ្ឋកិច្ចពិភពលោក។ ហើយសេដ្ឋកិច្ចពិភពលោក ត្រូវបានគេរំពឹងថានឹងនៅតែស្ថិតក្នុងគន្លងកំណើនវិជ្ជមាន

នៅឆ្នាំ២០២២ ជាមួយនឹងអត្រាខុសគ្នាទៅតាមប្រទេសផ្សេងៗ ដោយផ្អែកលើប្រសិទ្ធភាពនៃការគ្រប់គ្រងជំងឺកូវីដ១៩ និងគោលនយោបាយគាំទ្ររបស់រដ្ឋាភិបាលរៀងខ្លួនៗ។ ប៉ុន្តែ មេរោគបំប្លែងថ្មី នឹងនៅតែជាបញ្ហាប្រឈមដ៏សំខាន់នៅឆ្នាំនេះ រួមជាមួយនឹងដូចជាការប្រែប្រួលអាកាសធាតុ ភូមិសាស្ត្រនយោបាយ និងពាណិជ្ជកម្មផងដែរ។

ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកបន្តិចម្តងៗ នឹងគាំទ្រដល់ការនាំចេញរបស់កម្ពុជា ជាពិសេស ផលិតផលមិនមែនកាត់ដេរ ដូចជាគ្រឿងបន្លាស់ អគ្គិសនី និងកង់ ដែលស្របតាមយុទ្ធសាស្ត្រធ្វើពិពិធកម្ម។

ទន្ទឹមនឹងនេះ ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ជាមួយប្រទេសចិន និងកូរ៉េខាងត្បូងនឹងបង្កើតឱ្យមានកម្លាំងជម្រុញកាន់តែខ្លាំងសម្រាប់វិស័យកសិកម្ម

ពាណិជ្ជកម្ម ទំនិញ និងសេវាកម្ម លំហូរវិនិយោគ និងពាណិជ្ជកម្មអេឡិចត្រូនិក។

ជាមួយគ្នានេះ អត្រាអតិផរណាមានកម្រិត ២.៦% នៅឆ្នាំ២០២២ ធ្លាក់ចុះពី២.៩% នៅឆ្នាំ២០២១ ខណៈដែលអត្រាប្តូរប្រាក់ក្នុងស្រុកធៀបនឹងប្រាក់ដុល្លា នឹងនៅតែមានស្ថិរភាព គឺប្រហែល៤ ០៧៤រៀលក្នុងមួយដុល្លារ។ ទោះបីជាយ៉ាងណា កំណើនឥណទានខ្ពស់ និងការប្រមូលផ្តុំឥណទានក្នុងស្រុកក្នុងវិស័យសំណង់ និងអចលនទ្រព្យ នៅតែជាហានិភ័យដ៏សំខាន់ចំពោះស្ថិរភាពហិរញ្ញវត្ថុរបស់ កម្ពុជា។ *ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព ៖ PhnomPenhPost ចេញផ្សាយថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១*

## កម្ពុជានាំចេញអង្ករបានជាង ៦១០ ០០០តោន ក្នុងឆ្នាំ ២០២១



*ប្រភព៖ Khem Sovannara, Khmer Times ២០២២*

កម្ពុជា បាននាំចេញអង្ករចំនួន ៦១៧ ០៦៩តោន ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២១ ដោយមានប្រាក់ចំណេញជាង ៥២៧លានដុល្លារ យោងតាមការធ្វើបច្ចុប្បន្នភាពរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF) ដែលបង្ហាញថាការនាំចេញអង្ករសរុបបានថយចុះចំនួន ១០.៦៨% បើធៀបនឹងឆ្នាំ ២០២០។

ក្នុងចំណោមអង្ករដែលបាននាំចេញ មាន ៤៥៧ ៤១៥ តោន ឬ ៧៤.១៣% ជាអង្ករក្រអូប ខណៈអង្ករស មានចំនួន ២៤.១៦ % ឬ ១៤៩.០៨០ តោន និងអង្ករសំរោប ១.៧១% ឬ ១០ ៥៧៤ តោន។

ប្រទេសចិន គឺជាទីផ្សារធំបំផុតដែលនាំចូលអង្ករពីកម្ពុជា មានចំនួន ៣០៩ ៧០៩តោន បន្ទាប់មកសហភាពអឺរ៉ុប និងបណ្តាប្រទេសអាស៊ាន បានទិញផលិតផលចំនួន ១៥៥ ៧៧៣តោន និង ៦៣ ១៦៥តោននៃផលិតផលរៀងៗគ្នា។ ហើយអង្ករដែលនៅសល់ចំនួន៨៨ ៤២២ តោន ត្រូវបានដឹកជញ្ជូនទៅកាន់គោលដៅផ្សេងទៀត។ ដោយឡែក កម្ពុជា បាននាំចេញស្រូវចំនួន ៣.៥២ លានតោន ទៅកាន់ប្រទេសវៀតណាម កើនឡើង ៦១.១៦% ធៀបនឹងឆ្នាំមុន ដែលរកចំណូលបានជាង ៦៣១លានដុល្លារ។ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២*

## «ទឹកត្រីកំពត»ក្លាយជាផលិតផលសម្គាល់ភូមិសាស្ត្រ




*ដោយ ៖ ភ្នំពេញ ប៉ុស្តិ៍( ទឹកត្រីអ៊ីធេ ង្វូវ ហេង ដាក់តាំងលក់នៅផ្សារទំនើប )*

ទឹកត្រីកំពត មានប្រវត្តិតាំងពីសម័យសង្គមរាស្ត្រនិយម ដែលត្រូវបានមហាជនទទួលស្គាល់រសជាតិ និងក្លិនឈ្ងុយ ដោយសារទឹកត្រីកំពត ផលិតឡើងពីត្រីកាកើម ដែលជាប្រភេទត្រីមានប្រូតេអ៊ីនខ្ពស់។

អគ្គនាយកក្រុមហ៊ុនផលិតទឹកត្រីអ៊ីធេ ង៉ូវហេង កំពត បានលើកឡើងថា លោកបានបើកសិប្បកម្មផលិតទឹកត្រីម៉ាក្សនេះតាំងពីឆ្នាំ១៩៩៥មក ប៉ុន្តែអាជីវកម្មនេះមានការប្រកួតប្រជែងខ្លាំងជាមួយទឹកត្រីនាំចូល។

បច្ចុប្បន្នទឹកត្រីលោកបានចាប់យកចំណែកទីផ្សារបាន ៣០ ទៅ ៤០% នៅតាមបណ្តាផ្សារទំនើបនានានៅភ្នំពេញ និងតាមបណ្តាខេត្ត។ លោក មានមហិច្ឆតានាំទឹកត្រីកំពត ទៅដល់ទីផ្សារអន្តរជាតិឱ្យបានកាន់តែច្រើន។ បច្ចុប្បន្នលោកកំពុងរៀបចំសិប្បកម្មឱ្យមានលក្ខណៈស្តង់ដា និងមានការទទួលស្គាល់ជាអន្តរជាតិ។

ក្រសួងពាណិជ្ជកម្មបានកំណត់ផលិតផល «ទឹកត្រីកំពត» ជាផលិតផលសក្តានុពលក្នុងការកសាងកេរ្តិ៍ឈ្មោះជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដើម្បីធ្វើយ៉ាងណាឱ្យផលិតផលទឹកត្រីនៅក្នុងខេត្តនេះ មានការទទួលស្គាល់កាន់តែច្រើន និងអាចនាំចេញទៅទីផ្សារអន្តរជាតិ ដូចម្រេចកំពត។ ពេលនេះក្រុមការងារកំពុងប្រមូលធាតុចូលពីផលិតករ-អាជីវករ និងសហគ្រាសធុនតូច និងមធ្យម និងបានរៀបចំបង្កើតគណៈកម្មការបណ្តោះអាសន្ន ដើម្បីរៀបចំចងក្រងសៀវភៅបន្ទុកស្តីពីការផលិតទំនិញសម្គាល់ភូមិសាស្ត្រ «ទឹកត្រីកំពត» សៀវភៅលក្ខន្តិកៈសមាគម បទបញ្ជាផ្ទៃក្នុង គំរូរូបសញ្ញាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ទឹកត្រីកំពត» និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។ ដើម្បីអនុវត្តគម្រោងនេះឱ្យមានប្រសិទ្ធភាព ក្រសួងពាណិជ្ជកម្មគ្រោងអញ្ជើញតំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តំណាងក្រសួងកសិកម្ម និងអាជ្ញាធរមូលដ្ឋាន ដើម្បីចូលរួមរៀបចំចងក្រងសៀវភៅបន្ទុក ស្តីពីការផលិតទំនិញសម្គាល់ភូមិសាស្ត្រ «ទឹកត្រី

កំពត» សៀវភៅលក្ខន្តិកៈសមាគម បទបញ្ញាផ្ទៃក្នុង គំរូរូបសញ្ញាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ទឹកត្រីកំពត»។ បន្ទាប់ពីទទួលបានសមាសភាពក្រសួង និងអាជ្ញាធរពាក់ព័ន្ធ ក្រសួងពាណិជ្ជកម្មនឹងសហការរៀបចំកិច្ចប្រជុំពិភាក្សាបន្តនៅទីតាំងផ្ទាល់ (ខេត្តកំពត ឬខេត្តកែប) ដើម្បីប្រមូលធាតុចូល និងពិនិត្យទីតាំងផលិតកម្មផ្ទាល់ និងចងក្រងសៀវភៅបន្ទុកទឹកត្រីកំពត ដោយក្រសួងមានគម្រោងនឹងបញ្ចប់គម្រោងកសាងកេរ្ដិ៍ឈ្មោះ«ទឹកត្រីកំពត» ជាម៉ាក្សសម្គាល់ភូមិសាស្ត្រនៅចុងខែមេសា ឆ្នាំ ២០២២ ខាងមុខ។

ម្ចាស់សិប្បកម្មផលិតទឹកត្រីអ៊ីឆេ ង៉ូវហេង នេះបានបញ្ជាក់ថា លោកកំពុងពង្រីកសន្សឹមៗ ដោយសារយើងត្រូវការហិរញ្ញវត្ថុច្រើន ព្រោះវត្ថុធាតុដើមរបស់យើង គឺជាត្រីធម្មជាតិ ដែលមានរដូវកាល ១ ឆ្នាំម្តង ដូចនេះយើងត្រូវការប្រមូលទិញស្តុកទុក ដែលត្រូវការទីតាំងធំជាងមុន។ បើទឹកត្រីកំពត បានចុះបញ្ជីជាផលិតផលសម្គាល់ភូមិសាស្ត្រទៀតនោះ កេរ្ដិ៍ឈ្មោះទឹកត្រីកំពតកាន់តែល្បីល្បាញ និងងាយស្រួលក្នុងការនាំចេញ៕

*ដោយ ម៉ែន ខែមរៈ*

*<u>ប្រភព ៖ ភ្នំពេញ ប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១។</u>*

## គម្រោងពហុបំណងលើផ្ទៃដីជាង ៦ ពាន់ហិកតា គ្រោងអភិវឌ្ឍនៅខេត្តកោះកុង



*រូបថត រដ្ឋបាលស្រុក បូទុមសាគរ*

ក្រុមហ៊ុន អានកូ អាហរ័ណ នីហរ័ណ នឹងធ្វើការវិនិយោគលើផ្ទៃដីទំហំ ៦ ១៤៥,៩៦ ហិកតា ក្នុងឧទ្យានជាតិបទុមសាគរនៃខេត្តកោះកុង ដើម្បីទាក់ទាញវិនិយោគិនជាតិ និងអន្តរជាតិឱ្យទៅកាន់ខេត្តនេះកាន់តែច្រើន។ គម្រោងអភិវឌ្ឍនេះនឹងផ្តោតសំខាន់ទៅលើការសាងសង់សណ្ឋាគារលំដាប់ផ្កាយ ៥ មណ្ឌលកម្សាន្តរមណីយដ្ឋាន និងរៀបចំទៅជាកន្លែងសម្រាប់បម្រើឱ្យការវិនិយោគ និងទេសចរណ៍រួមជាមួយគម្រោងជាច្រើនទៀត។

អភិបាលរងខេត្តកោះកុងបានលើកឡើងថា គម្រោងនេះត្រូវបានស្រុកបទុមសាគរ និងស្រុកគិរីសាគរ ព្រមទាំងរដ្ឋបាលខេត្ត និងក្រសួងបរិស្ថានឯកភាពគ្នារួចហើយ ប៉ុន្តែមិនទាន់មានការឯកភាពពីរាជរដ្ឋាភិបាលនៅឡើយទេ។ នៅក្នុងតំបន់នេះមានគម្រោងវិនិយោគធំៗ បានបង្ហាញខ្លួនជាច្រើនផងដែរ ដូចជា ព្រលានយន្តហោះតារាសាគរ កម្រិត4E កំពង់ផែទឹកជ្រៅ ផ្លូវជាតិលេខ៤៨ ផ្លូវជាតិលេខ១០ រួមទាំងគម្រោងអភិវឌ្ឍន៍ដ៏សន្ធឹកសន្ធាប់ផ្សេងទៀត។

ប្រធានសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា បានលើកឡើងថា ខេត្តកោះកុងសម្បូរធនធានធម្មជាតិល្អស្អាត សម្រាប់វិស័យទេសចរណ៍ ដែលមិនមានខេត្តណាមានដូចខេត្តនេះទេ។ កន្លងមកខេត្តមួយនេះកម្សត់ជាងខេត្តដទៃ ព្រោះមិនសូវមានអ្នកវិនិយោគចូលបណ្តាក់ទុនច្រើន ដោយសារបញ្ហាភ្លើងអគ្គិសនីមិនមានគ្រប់គ្រាន់ ដែលជាឧបសគ្គមួយក្នុងចំណោមឧបសគ្គដទៃជាច្រើនផ្សេងទៀត។ ខេត្តកោះកុងមានចម្ងាយផ្លូវជិតជាងខេត្តមណ្ឌលគិរី ប៉ុន្តែបើគិតពីការអភិវឌ្ឍ គឺគេមើលមិនសូវឃើញទេ ខណៈពេលដែលខេត្តនេះ មានសក្តានុពលខ្លាំង។ លោករំពឹងថា រដ្ឋាភិបាលនឹងស្វែងរកគន្លឹះសំខាន់ៗដើម្បីដោះស្រាយរាល់

ឧបសគ្គដែលរាំងស្ទះដល់អ្នកវិនិយោគជាតិ-អន្តរជាតិ អាចឱ្យចូលបណ្តាក់ទុនលើគ្រប់វិស័យ ដើម្បីឱ្យខេត្តនេះ មានការអភិវឌ្ឍរីកចម្រើនបន្ថែមទៀត និងផ្តល់ចំណូលដល់សេដ្ឋកិច្ចជាតិ និងប្រជាជនមូលដ្ឋានឱ្យកាន់តែមានជីវភាពធូរធារបន្ថែមទៀត៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។*

*ប្រភព ៖ Kampucheathmey ចេញផ្សាយថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ ការប្រៀបធៀបទីផ្សារគោលដៅនាំចេញកម្ពុជារយៈពេល១០ខែ ឆ្នាំ២០២១

ស្ថិតិនាំចេញកម្ពុជាជាមួយដៃគូសំខាន់ៗ រយៈពេល១០ខែដើម ឆ្នាំ២០២១ (ឯកតា៖ លានដុល្លារអាមេរិក)

| ល.រ | ប្រទេសដៃគូនាំចេញរបស់កម្ពុជា | រយៈពេល ១០ខែឆ្នាំ ២០២០ | រយៈពេល ១០ខែ ឆ្នាំ ២០២១ | កំណើន (%) |
|---|---|---|---|---|
| | សរុប | 14550 | 14286 | -2% |
| 1 | សហរដ្ឋអាមេរិក | 4328 | 6075 | 40% |
| 2 | ជប៉ុន | 874 | 920 | 5% |
| 3 | ចិន | 820 | 1222 | 49% |
| 4 | ចក្រភពអង់គ្លេស | 700 | 599 | -14% |
| 5 | កាណាដា | 604 | 790 | 31% |
| 6 | កូរ៉េ | 152 | 157 | 3% |
| 7 | អូស្ត្រាលី | 115 | 151 | 31% |
| 8 | ឥណ្ឌា | 52 | 100 | 92% |
| 9 | នូវែលសេឡង់ | 11 | 13 | 18% |
| 10 | អាស៊ាន | 3496 | 960 | -73% |
| | ថៃ | 591 | 289 | -51% |
| | វៀតណាម | 280 | 409 | 46% |
| 11 | សហភាពអឺរ៉ុប(EU) | 2585 | 2619 | 1% |
| 12 | សហភាពសេដ្ឋកិច្ចអឺរ៉ុបអាស៊ី(EAEU) | 43 | 46 | 7% |
| 13 | ប្រទេសផ្សេងៗ | 772 | 635 | -18% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ចុះនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១*

តារាងទី១ខាងលើនេះបានបង្ហាញ ពីការប្រៀបធៀបស្ថិតិនាំចេញកម្ពុជាជាមួយដៃគូសំខាន់ៗក្នុងរយៈពេល១០ខែដើម ឆ្នាំ២០២១ ដែលមានកំណើនថយ ២% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ទំនិញនាំចេញទាំងនេះរួមមាន ៖ សម្លៀកបំពាក់ ស្បែកជើង សម្ភារៈធ្វើដំណើរ ម៉ាស៊ីនបរិធាននិងសម្ភារៈអគ្គិសនី អង្ករ កង់ គ្រឿងសង្ហារឹមនិងបរិធានបំភ្លឺ កៅស៊ូក្រែប ស្ករអំពៅ បន្លែនិងផ្លែឈើ និងមុខទំនិញផ្សេងទៀត។ ទំនិញនាំចេញទាំងនេះ ត្រូវបាននាំចេញទៅប្រទេសគោលដៅជាច្រើនដូចជា៖ សហរដ្ឋអាមេរិក ជប៉ុន ចិន ចក្រភពអង់គ្លេស កាណាដា កូរ៉េ អូស្ត្រាលី ឥណ្ឌា នូវែលសេឡង់ អាស៊ាន សហភាពអឺរ៉ុប(EU) សហភាពសេដ្ឋកិច្ចអឺរ៉ូប អាស៊ី (EAEU) និងប្រទេសផ្សេងៗ បើយោងតាមរបាយការណ៍របស់ក្រសួងពាណិជ្ជកម្មកម្ពុជា ដែលបានចេញផ្សាយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១។

គិតត្រឹមរយៈពេល១០ខែឆ្នាំ២០២១នេះ ការនាំចេញលើមុខទំនិញទាំងអស់ខាងលើនេះ មានការកើនឡើងខ្លាំង៩២% ទៅទីផ្សារឥណ្ឌា។ កំណើន ៤៩%, ៤៦%, ៤០%, ៣១%, ១៨%, ៧%, ៥%, ៣%, ១% រៀងគ្នាទៅកាន់ទីផ្សារចិន វៀតណាម សហរដ្ឋអាមេរិក កាណាដា នូវែលសេឡង់ សហភាពសេដ្ឋកិច្ចអឺរ៉ុបអាស៊ី(EAEU) ជប៉ុន កូរ៉េ និងសហភពអឺរ៉ូប(EU) បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។

រីឯការនាំចេញទៅអាស៊ាន មានការធ្លាក់ចុះយ៉ាងខ្លាំង ៧៣% ក្នុងនោះ ទីផ្សារថៃធ្លាក់ចុះ ៥១%។ បន្ទាប់មកប្រទេសផ្សេងៗថយចុះ១៨% និងចក្រភពអង់គ្លេសថយចុះ១៤% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០៕ *ដោយ ឈន ហាំ*

## តារាងទី២៖ ការប្រៀបធៀបទីផ្សារនាំចូលរបស់កម្ពុជា រយៈពេល១០ខែ ឆ្នាំ២០២១

ស្ថិតិនាំចូលកម្ពុជាជាមួយដៃគូសំខាន់ៗ រយៈពេល១០ខែដើម ឆ្នាំ២០២១ (ឯកតា៖ លានដុល្លារអាមេរិក)

| ល.រ | ប្រទេសដៃគូនាំចូលរបស់កម្ពុជា | រយពេល ១០ខែឆ្នាំ ២០២០ | រយៈពេល ១០ខែ ឆ្នាំ ២០២១ | កំណើន (%) |
|---|---|---|---|---|
| | សរុប | 14624 | 23060 | 58% |
| 1 | សហរដ្ឋអាមេរិក | 196 | 278 | 42% |
| 2 | ជប៉ុន | 524 | 529 | 1% |
| 3 | ចិន | 5626 | 7760 | 38% |
| 4 | ចក្រភពអង់គ្លេស | 42 | 47 | 12% |
| 5 | កាណាដា | 48 | 32 | -33% |
| 6 | កូរ៉េ | 426 | 481 | 13% |
| 7 | អូស្ត្រាលី | 63 | 89 | 41% |
| 8 | ឥណ្ឌា | 106 | 144 | 36% |
| 9 | នូវែលសេឡង់ | 12 | 12 | 0% |
| 10 | **អាស៊ាន** | 5808 | 10389 | 79% |
| | ថៃ | 2320 | 2742 | 18% |
| | វៀតណាម | 2130 | 2530 | 19% |
| 11 | សហភាពអឺរ៉ុប(EU) | 562 | 864 | 54% |
| 12 | សហភាពសេដ្ឋកិច្ចអឺរ៉ូបអាស៊ី(EAEU) | 11 | 39 | 255% |
| 13 | ប្រទេសផ្សេងៗ | 1199 | 2395 | 100% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១*

តារាងទី២ ខាងលើនេះបានបង្ហាញ ពីការប្រៀបធៀបស្ថិតិនាំចូលមកកម្ពុជារវាងដៃគូសំខាន់ៗ ក្នុងរយៈពេល១០ខែដើម ឆ្នាំ២០២១ ដែលមានកំណើន ៥៨% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។

ទំនិញនាំចូលទាំងនេះមានដូចជា ៖ វាយនភ័ណ្ឌ សម្ភារៈសំណង់ ដែក ស៊ីម៉ង់ត៍ ទឹកបរិសុទ្ធ ស្រាបៀរនិងស្រាចំរុះ រថយន្ត ផលិតផលឱសថ ជីកសិកម្មនិងថ្នាំ គ្រឿងអេឡិចនិងសម្ភារៈអគ្គិសនី និងមុខទំនិញផ្សេងទៀត។ បើយោងតាមរបាយការណ៍របស់ ក្រសួងពាណិជ្ជកម្មកម្ពុជា ដែលបានចេញផ្សាយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១។ គិតត្រឹមរយៈពេល១០ខែ ឆ្នាំ២០២១នេះ ការនាំចូលមុខទំនិញទាំងអស់ខាងលើនេះ មកកម្ពុជាមានកំណើនយ៉ាងខ្លាំង ២៥៥% ពីទីផ្សារសហភាពសេដ្ឋកិច្ចអឺរ៉ុបអាស៊ី(EAEU) និងកំណើន១០០% មកពីប្រទេសផ្សេងៗ។ កំណើន ៧៨% មកពីអាស៊ាន ក្នុងនោះកំណើន១៨% មកពីថៃ និងកំណើន១៩% មកពីវៀតណាម។ កំណើន ៥៤%, ៤២%, ៤១%, ៣៨%, ៣៦%, ១៣%, ១២%, ១% រៀងគ្នា មកពីសហភាពអឺរ៉ុប(EU) សហរដ្ឋអាមេរិក អូស្ត្រាលី ចិន ឥណ្ឌា កូរ៉េ ចក្រភពអង់គ្លេស ជប៉ុន និងនូវែលសេឡង់ពុំមានកំណើនទេដែលមានតម្លៃស្មើ ១២ លានដុល្លារអាមេរិក បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ លើកលែងតែមកពីប្រទេសកាណាដាមួយប៉ុណ្ណោះ មានកំណើនថយចុះ ៣៣% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០៕

*ដោយ ឈន ហាំ*

## តារាងទី៣៖ ការប្រៀបធៀបទំហំពាណិជ្ជកម្មកម្ពុជា រយៈពេល១០ខែដើមឆ្នាំ២០២១

ស្ថិតិទំហំពាណិជ្ជកម្មកម្ពុជាជាមួយដៃគូសំខាន់ៗរយៈពេល១០ខែដើម ឆ្នាំ២០២១ (ឯកតា៖ លានដុល្លារអាមេរិក)

| ល.រ | ប្រទេសដៃគូពាណិជ្ជជាមួយកម្ពុជា | ទំហំពាណិជ្ជកម្មរយៈពេល១០ខែឆ្នាំ២០២០ | ទំហំពាណិជ្ជកម្មរយៈពេល១០ខែឆ្នាំ២០២១ | កំណើន (%) |
|---|---|---|---|---|
| | សរុប | 29174 | 37346 | 28% |
| 1 | សហរដ្ឋអាមេរិក | 4523 | 6353 | 40% |
| 2 | ជប៉ុន | 1398 | 1449 | 4% |
| 3 | ចិន | 6446 | 8982 | 39% |
| 4 | ចក្រភពអង់គ្លេស | 742 | 645 | -13% |
| 5 | កាណាដា | 652 | 822 | 26% |
| 6 | កូរ៉េ | 578 | 638 | 10% |
| 7 | អូស្ត្រាលី | 176 | 239 | 36% |
| 8 | ឥណ្ឌា | 157 | 244 | 55% |
| 9 | នូវែលសេឡង់ | 23 | 25 | 9% |
| 10 | អាស៊ាន | 9304 | 11349 | 22% |
| | ថៃ | 2911 | 3031 | 4% |
| | វៀតណាម | 2411 | 2939 | 22% |
| 11 | សហភាពអឺរ៉ុប(EU) | 3148 | 3482 | 11% |
| 12 | សហភាពសេដ្ឋកិច្ចអឺរ៉ុបអាស៊ី(EAEU) | 54 | 84 | 56% |
| 13 | ប្រទេសផ្សេងៗ | 1971 | 3031 | 54% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្មកម្ពុជា ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១*

តារាងទី៣ ខាងលើនេះបានបង្ហាញ ពីការប្រៀបធៀបស្ថិតិទំហំពាណិជ្ជកម្មកម្ពុជារវាងដៃគូសំខាន់ៗ ចាប់ពីខែមករា ដល់ខែតុលា ឆ្នាំ២០២១ ដែលមានកំណើន ២៨% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។

គិតត្រឹមរយៈពេល១០ខែឆ្នាំ២០២១នេះ ទំហំពាណិជ្ជកម្មកម្ពុជារវាងដៃគូផ្សេងៗ រួមមាន៖ ទំហំពាណិជ្ជកម្មរវាងកម្ពុជាជាមួយ សហភាពសេដ្ឋកិច្ចអឺរ៉ុបអាស៊ី(EAEU) ឥណ្ឌា និងប្រទេសផ្សេងៗ មានកំណើន ៥៦%, ៥៥%, ៥៤% រៀងគ្នា។ កំណើន ៤០%, ៣៩%, ២៦%, ១១%, ១០%, ៩%, ៤% រៀងគ្នា ទំហំពាណិជ្ជកម្មកម្ពុជាជាមួយ សហរដ្ឋអាមេរិក ចិន កាណាដា សហភាពអឺរ៉ុប (EU) កូរ៉េ និងនូវែលសេឡង់។ ទំហំពាណិជ្ជកម្មកម្ពុជាជាមួយទីផ្សារអាស៊ានមានកំណើន២២% ក្នុងនោះរវាងវៀតណាមកើន ២២% និងថៃកើន៤% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ រីឯទំហំពាណិជ្ជកម្មកម្ពុជា រវាងទីផ្សារចក្រភពអង់គ្លេស មានកំណើនថយចុះ ១៣% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០៕

## ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### កម្ពុជារំពឹងស្រូបទាញទីផ្សារអឺរ៉ុប ៤០%មកវិញ ក្រោយអឺរ៉ុបលើកលែងពន្ធលើការនាំចូលអង្ករពីកម្ពុជា



*រូបភាព៖ អ៊ិនធឺណែត(ការនាំចេញអង្កររបស់កម្ពុជា)*

បើគ្មានអ្វីប្រែប្រួលទេ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ ខាងមុខនេះតទៅ សភាពាណិជ្ជកម្មសហភាពអឺរ៉ុប នឹងលើកលែងការយកពន្ធលើអង្ករនាំចូលគ្រប់ប្រភេទពីកម្ពុជាឡើងវិញហើយ បន្ទាប់ពីអឺរ៉ុបបានកំណត់យកពន្ធអស់រយៈពេលប្រមាណ៣ឆ្នាំកន្លងមកនេះ។

ប្រមាណ៣ឆ្នាំកន្លងមកនេះ ការនាំចេញអង្ករពីកម្ពុជាទៅកាន់ទីផ្សារអឺរ៉ុបបានធ្លាក់ចុះក្នុងរង្វង់ជាង១០%ក្នុងមួយឆ្នាំៗ។ នៅឆ្នាំ២០២១ ការនាំចេញទៅទីផ្សារអឺរ៉ុបសម្រេចបានប្រមាណ១៤ម៉ឺនតោនតែប៉ុណ្ណោះ។

អគ្គលេខាធិការនៃសហព័ន្ធស្រូវអង្ករកម្ពុជា រំពឹងថា ការនាំចេញអង្កររបស់កម្ពុជា នឹងមានភាពល្អប្រសើរឡើងវិញ ដូចពេលមិនទាន់មានការដាក់ទណ្ឌកម្មដូច្នោះដែរ។ តាមរយៈការលើកលែងពន្ធនាំចូលនេះ ការនាំចេញ

អង្ករពីកម្ពុជាទៅកាន់ទីផ្សារសហភាពអឺរ៉ុប អាចក្តោបទីផ្សារបានជាង៤០% នៃការនាំចេញអង្ករសរុបឡើងវិញនៅក្នុងឆ្នាំ ២០២២នេះ។

គួររំលឹកថា សភាពាណិជ្ជកម្មសហភាពអឺរ៉ុបបានសម្រេចយកពន្ធលើការនាំចូលអង្ករពីកម្ពុជា ក្នុងអត្រាពន្ធជិត២០០ដុល្លារសម្រាប់អង្ករ១តោន កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩។ បន្ទាប់មកពន្ធនេះ បានធ្លាក់មកនៅត្រឹមជាង១៧០ដុល្លារក្នុង១តោន នៅឆ្នាំ២០២០ និងបន្តធ្លាក់មក១៤១ដុល្លារក្នុង១តោន នៅឆ្នាំ២០២១។ ការកំណត់យកពន្ធអង្ករនាំចូលពីកម្ពុជាក្នុងរយៈពេល ៣ឆ្នាំកន្លងមកនេះ គឺដោយសារតែមានការប្តឹងជំទាស់ពីបណ្តាប្រទេសមួយចំនួននៃសភាព អឺរ៉ុប ដែលថា អង្ករនាំចូលពីកម្ពុជាទៅអឺរ៉ុបមានចំនួនច្រើន និងបានធ្វើប៉ះពាល់ដល់ប្រយោជន៍ប្រទេសអ្នកផលិតអង្ករដូចគ្នានេះនៅអឺរ៉ុប៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២។*

## ការកកស្ទះទំនិញអូសបន្លាយពេលយូរនៅច្រកព្រំដែនចិន-វៀតណាម បង្កផលប៉ះពាល់កម្រិតណាដល់ការដឹកជញ្ជូនរបស់កម្ពុជា?



*ដោយ ខេមបូណូមីស(កុងតឺន័រទំនិញកកស្ទះនៅនៅច្រកព្រំដែន ចិន-វៀតណាម)*

រដ្ឋាភិបាលក្រុងប៉េកាំង នៅតែបន្តអនុវត្តនូវគោលនយោបាយ គ្មានកូវីដ(Zero Covid) ទោះជាបច្ចុប្បន្នប្រទេសនេះមានករណីឆ្លងតិចតួច បើប្រៀបនឹងប្រទេសដទៃ។ ការអនុវត្តគោលនយោបាយនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងលើវិស័យដឹកជញ្ជូន ពិសេសប្រទេសវៀតណាម រួមទាំងប្រទេសកម្ពុជាផងដែរ។ បញ្ហាកកស្ទះឡានកុងតឺន័រដឹកទំនិញរាប់ពាន់គ្រឿងនៅតាមព្រំដែនរវាងវៀតណាម និងចិន នៅតែបន្តអូសបន្លាយពេលយូរជាច្រើនខែមកហើយ នៅតែមិនទាន់មានដំណោះស្រាយបាន។

ក្រសួងពាណិជ្ជកម្មកម្ពុជា បានជូនដំណឹងនេះដល់សមាគមដឹកជញ្ជូននៅកម្ពុជា ប្តូរការដឹកជញ្ជូនទៅប្រទេសចិន តាមផ្លូវទឹកវិញ ដើម្បីចៀសវាងនូវហានិភ័យ ដែលអាចកើតឡើង ជាយថាហេតុ។

ប្រធានសមាគមភស្តុភារកម្មកម្ពុជាបានអះអាងដែរថា បញ្ហាកកស្ទះទំនិញនៅច្រកទ្វារព្រំដែនវៀតណាម និងប្រទេសចិន មិនបានជះឥទ្ធិពលធ្ងន់ធ្ងរដល់វិស័យដឹកជញ្ជូននៅកម្ពុជាទេ ព្រោះខាងសមាគមបានដឹងជាមុនទៅហើយនូវបញ្ហាដែលបានកើតឡើងខាងលើ ហើយសមាគមបានជំរុញការដឹកជញ្ជូនតាមផ្លូវទឹកវិញ។

ម្យ៉ាងទៀត ទំនិញកម្ពុជា ដែលនាំទៅប្រទេសចិន ឆ្លងកាត់វៀតណាម មានចំនួនតិចតួចបំផុត ហើយមកដល់ពេលនេះ ទំនិញកម្ពុជា ទៅកាន់ប្រទេសចិន នៅតែអាចដំណើរការជាធម្មតា។

សកម្មភាពនាំចូល និងនាំចេញនៅច្រកព្រំដែនវៀតណាម និងចិន បានជួបប្រទះកកស្ទះយ៉ាងខ្លាំង ពិសេសនៅច្រកទ្វារព្រំដែនខេត្ត ឡាក់ សឺន (Lang Son) និងខេត្តគ័ង នីញ (Quang Ninh) ដែលបណ្តាលមកពីការរឹតត្បិតវិធានការបង្ការការឆ្លងរាលដាលជំងឺកូវីដ-១៩ របស់ប្រទេសចិន។ គិតត្រឹមថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ មានរថយន្តជាង ៦ពាន់គ្រឿង កំពុងរង់ចាំការនាំចេញទៅប្រទេសចិន។ ថ្មីៗនេះវៀតណាម បានស្នើឱ្យភាគីចិនបើកច្រកព្រំដែនឱ្យចរាចរទំនិញឡើងវិញផងដែរ ប៉ុន្តែ នៅមិនទាន់មានការឆ្លើយតបបែបណានៅឡើយទេ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីសចេញផ្សាយថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២។*

## ផលិតផលក្នុងស្រុកសរុប (GDP)របស់ប្រទេសសិង្ហបុរី ឆ្នាំ២០២១ បានកើនឡើងក្នុងល្បឿនលឿនបំផុត គិតក្នុងរយៈពេលជាងមួយទសវត្សន៍កន្លងមក



*ប្រភព៖asia financial, 2021 រូបភាព៖ Allianz*

កំណើនសេដ្ឋកិច្ចរបស់សិង្ហបុរីបានកើនឡើង ៧,២% ក្នុងឆ្នាំ២០២១ ដែលនេះជាទិន្នន័យមួយខ្ពស់បំផុតក្នុងរយៈពេល១០ឆ្នាំចុងក្រោយស្របតាមការព្យាករផ្លូវការរបស់រដ្ឋាភិបាល ខណៈដែលខ្លួនទើបងើបចេញពីវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩និងការធ្លាក់ចុះសេដ្ឋកិច្ច៥,៤%ក្នុងឆ្នាំ ២០២០។ វិស័យហិរញ្ញវត្ថុ និងការដឹកជញ្ជូន គឺជាចំណុចទាញនៃកំណើនសកលលោក បានចាប់ផ្តើមការងើបឡើងវិញជាបន្តបន្ទាប់ នៅពេលដែលរដ្ឋាភិបាលជុំវិញពិភពលោកផ្លាស់ប្តូរយុទ្ធសាស្ត្រនៃមេរោគឆ្លងរបស់ពួកគេត្រូវរៀនរស់នៅជាមួយជំងឺរាតត្បាត ។

ផ.ស.ស.ប្រចាំឆ្នាំរបស់ប្រទេសសិង្ហបុរី កើនឡើងខ្លាំងបំផុត១៤,៥% ក្នុងឆ្នាំ២០១០ នៅពេលដែលសេដ្ឋកិច្ចបានងើបចេញពីវិបត្តិហិរញ្ញវត្ថុពិភពលោក។ អ្នកសេដ្ឋកិច្ចលោក Jeff Ng បានបញ្ជាក់ថា កំណើននឹងមានការកើនឡើង នៅពេលដែលសេដ្ឋកិច្ចពិភពលោកចាប់ផ្តើមមានភាពប្រសើរឡើង នឹងជួយដល់លក្ខខណ្ឌតម្រូវការខាងក្រៅសម្រាប់ប្រទេសសិង្ហបុរីផងដែរប៉ុន្តែការគំរាមកំហែងចម្លងនៅតែបន្តគឺអតិផរណា។

យោងតាមសេចក្តីថ្លែងការណ៍មួយ,ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មបានបង្ហាញថា៖ផ.ស.សបានកើនឡើង៥,៩% ក្នុងខែតុលា ដល់ខែធ្នូ ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុនលឿនជាងការព្យាករណ៍កំណើន ៥,៤% នៅក្នុងការស្ទង់មតិរបស់ Reuters លើអ្នកវិភាគសេដ្ឋកិច្ច។ ផ.ស.ស បានកើនឡើង ២,៦% លើមូលដ្ឋានដែលបានកែតម្រូវតាមរដូវកាលប្រចាំត្រីមាសក្នុងខែតុលាដល់ខែធ្នូ ដែលខ្ពស់ជាងកំណើន ១,២% នៅក្នុងត្រីមាសមុន។ ស្របពេលជាមួយគ្នានេះដែររដ្ឋាភិបាលបានធ្វើការព្យាករណ៍ថា ផ.ស.ស នឹងកើនឡើងពី៣% ទៅ៥% នៅឆ្នាំ ២០២២។

លោកនាយករដ្ឋមន្ត្រី Lee Hsien Loong បានមានប្រសាសន៍ថា៖ សេដ្ឋកិច្ចរបស់សិង្ហបុរីកំពុងងើបឡើងវិញជាលំដាប់ដូចនេះរដ្ឋាភិបាលមើលឃើញពីសន្ទុះនៃតម្រូវការក្នុងស្រុកមានភាពប្រសើរឡើង ទើបចាប់ផ្តើមដំឡើងពន្ធលើការលក់។ រដ្ឋាភិបាលបានដាក់ផែនការដំឡើងពន្ធលើទំនិញ និងសេវាកម្មពី ២ %ដល់ ៩ %ចន្លោះឆ្នាំ ២០២២ ដល់ ២០២៥។*ដោយ សេន ចន្ទី*

*ប្រភព៖asiafinancial,ចេញផ្សាយថ្ងៃទី០៣ខែមករា ឆ្នាំ២០២១*

## គម្រោងវិនិយោគសាធារណៈរបស់ប្រទេសវៀតណាមទៅលើឧស្សាហកម្មដឹកជញ្ជូនផ្តោតសំខាន់លើការ ដឹកជញ្ជូនតាមផ្លូវសមុទ្រ




*ប្រភព៖vietnamnews, 2021 រូបភាព៖ VNA / VNS*

យោងតាមក្រសួង ដឹកជញ្ជូន ផ្នែកផ្លូវដែក និងអាកាសចរណ៍ បានបញ្ជាក់ថា ឧស្សាហកម្មដឹកជញ្ជូនបានលើកកម្ពស់ផ្នែកដឹកជញ្ជូនតាមសមុទ្រ និងពន្លឿនការអនុវត្តគម្រោងវិនិយោគសាធារណៈ ដើម្បីទូទាត់ការខាតបង់ក្នុង

ផ្នែកផ្លូវថ្នល់ ផ្លូវរថភ្លើង និងផ្នែកដឹកជញ្ជូនអាកាសចរណ៍ដែលមានកំណើនអវិជ្ជមានក្នុងឆ្នាំ២០២១ ដោយសារតែផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩។

ផ្លូវដែក Vietnam Railways របស់រដ្ឋាភិបាលបានបរាជ័យក្នុងការបំពេញតាមគោលដៅកំណើនប្រចាំឆ្នាំក្នុងឆ្នាំ ២០២១ ដោយសារប្រាក់ចំណូល និងប្រាក់ចំណេញបានធ្លាក់ចុះ ១៦,៣% និង ៤៧,២% រៀងគ្នាធៀបនឹងឆ្នាំ២០២០។ សម្រាប់ផ្នែកដឹកជញ្ជូនតាមផ្លូវអាកាសក៏ប្រឈមនឹងការខាតបង់ធំក្នុងឆ្នាំនេះផងដែរ ដោយសារការដឹកជញ្ជូនអ្នកដំណើរអន្តរជាតិបានធ្លាក់ចុះ៩៣%បើធៀបនឹងឆ្នាំ ២០២០។

លោក Pham Việt Dũng ប្រធានសមាគមធុរកិច្ចអាកាសចរណ៍វៀតណាម បានបង្ហាញថា៖ក្នុងអំឡុងការផ្ទុះជំងឺរាតត្បាតចុងក្រោយនេះ ប្រាក់ចំណូលរបស់ក្រុមហ៊ុនអាកាសចរណ៍បានធ្លាក់ចុះ ពី៨០%ទៅ៩០% ដូចនេះ ដើម្បីទូទាត់ការលំបាក រដ្ឋាភិបាលបានជំរុញផ្នែកដឹកជញ្ជូនតាមសមុទ្រវិញម្តង។

លោក Nguyễn Đình Việt អនុប្រធានរដ្ឋបាលដែនសមុទ្រវៀតណាមបានមានប្រសាសន៍ថា ដោយសារការអនុវត្តយ៉ាងសកម្មនូវដំណោះស្រាយជាច្រើន បរិមាណទំនិញសរុបតាមរយៈប្រព័ន្ធកំពង់ផែសមុទ្ររបស់វៀតណាមត្រូវបានប៉ាន់ប្រមាណថាមានជាង ៧០៣ លានតោនក្នុងឆ្នាំ ២០២១ កើនឡើង ២ %បើធៀបនឹងឆ្នាំ ២០២០។ សរុបមក បរិមាណទំនិញនាំចេញមានជាង ១៨៤ លានតោនកើនឡើង ៤ % ហើយបរិមាណទំនិញក្នុងស្រុកកើនឡើង ៥%។ គួរកត់សម្គាល់ថា ក្រសួងដឹកជញ្ជូនបានចេញដំណោះស្រាយជាច្រើន ដើម្បីជំរុញការអនុវត្តគម្រោងវិនិយោគសាធារណៈនៅឆ្នាំ២០២១។

រដ្ឋាភិបាលវៀតណាមបានប្រគល់ថវិកាឱ្យក្រសួងដឹកជញ្ជូនដើម្បីអនុវត្តការចាយវាយប្រមាណ ៤៣,៤ ទ្រីលានដុងសម្រាប់គម្រោងវិនិយោគសាធារណៈក្នុងឆ្នាំ ២០២១។ តាមការប៉ាន់ស្មាន ក្រសួងនឹងបំពេញការងារបានជាង ៩៥ %នៃការងារដែលបានចាត់តាំងដោយ ចុងខែមករា ឆ្នាំ ២០២២ បំពេញតាមផែនការរបស់រដ្ឋាភិបាល។ លទ្ធផលនេះនឹងជួយឱ្យក្រសួងដឹកជញ្ជូនស្ថិតក្នុងចំណោមក្រសួង និងទីភ្នាក់ងារមួយចំនួនដែលទទួលបានអត្រាចំណាយខ្ពស់បំផុតនៅក្នុងប្រទេស។

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ ២០២១ ក្រសួងបានបញ្ចប់គម្រោងចំនួន ១៤ និងបានចាប់ផ្តើមគម្រោងចំនួន ១៨ ផ្សេងទៀត រួមទាំងផ្លូវ North-South Expressway និង Cát Linh-Hà Đông Urban Railway។

នៅឆ្នាំ ២០២២ ក្រសួងដឹកជញ្ជូនត្រូវបានចាត់តាំងដោយនាយករដ្ឋមន្ត្រីឱ្យអនុវត្តគម្រោងនានាក្នុងផែនការវិនិយោគសាធារណៈរយៈពេលមធ្យមរបស់ប្រទេសដែលមានតម្លៃសរុបជាង ៥០ ទ្រីលានដុង។ ដើម្បីសម្រេចបានគោលដៅ រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន លោក Nguyễn Văn Thể បានស្នើឱ្យបង្កើតក្រុមការងារពិសេសមួយក្នុងការជំរុញការបញ្ចេញទុនវិនិយោគសាធារណៈសម្រាប់គម្រោងក្នុងវិស័យដឹកជញ្ជូនដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងសម្រេចបាននូវសេដ្ឋកិច្ចសង្គមខ្ពស់បំផុត៕

*ដោយ សេន ចន្ទី*

*ប្រភព៖vietnamnews,ចេញផ្សាយថ្ងៃទី០៤ខែមករា ឆ្នាំ២០២១*

## ពាណិជ្ជកម្មថៃ សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២១ (គិតជាពាន់លានបាត)

ការនាំចេញរបស់ប្រទេសថៃបានកើនឡើងច្រើនជាងការរំពឹងទុកនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ធៀបនឹងឆ្នាំមុន ដោយសារតម្រូវការសកលកាន់តែខ្លាំង និងប្រាក់បាតធ្លាក់ចុះ។ការនាំចេញដែលជាកត្តាជំរុញដ៏សំខាន់នៃកំណើនរបស់ប្រទេសបានកើនឡើង២៤,៧% នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។ ការនាំចេញទៅកាន់សហរដ្ឋ

អាមេរិក ដែលជាទីផ្សារដ៏ធំបំផុតកើនឡើង ២០,៥% ធៀបនឹងឆ្នាំ២០២០។ ការនាំចេញទៅប្រទេសចិន បានកើនឡើង ២៤,៣% ប៉ុន្តែការនាំចេញទៅប្រទេស ជប៉ុនបានធ្លាក់ចុះ ០,១%។

រីឯ ការនាំចូលរបស់ថៃបានកើនឡើង ២០,៥% នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ធៀបនឹងឆ្នាំមុន ដែលនាំឱ្យមានអតិរេកពាណិជ្ជកម្មចំនួន ១៤០,៤ ពាន់លានបាត សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២១៕

*ដោយ ជឹម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ៧៧៤,៩ |
| ការនាំចេញ | ៦៣៤,៧ |
| តុល្យភាពពាណិជ្ជកម្ម | 140,២ |

*ប្រភព៖ www.bot.or.th*

**ពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្ដាលខែ ដំបូងនៃខែវិច្ឆិកា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)**

យោងតាមស្ថិតិគយប្រទេសវៀតណាមបានបង្ហាញថា ការនាំចេញសរុបរបស់ប្រទេសវៀតណាម មានចំនួន ១៤,៦១ ពាន់លានដុល្លារ ខណៈការនាំចូលមានចំនួន ១៤,៩៨ ពាន់លានដុល្លារ។ ដូច្នេះ ប្រទេសវៀតណាម មានឱនភាពពាណិជ្ជកម្មចំនួន ០,៣៧ ពាន់លានដុល្លារ សម្រាប់រយៈពេលពាក់កណ្ដាលខែដំបូង នៃខែវិច្ឆិកា ឆ្នាំ២០២១។

បើធៀបទៅនឹងពាក់កណ្ដាលខែចុងក្រោយ នៃខែតុលា ឆ្នាំ២០២១ ការនាំចេញបានថយចុះដល់ ៦,៨%។ ការថយចុះនោះភាគច្រើន គឺបណ្ដាលមកពីការធ្លាក់ចុះនៃការនាំចេញទូរស័ព្ទ ទូរស័ព្ទដៃ និងគ្រឿងបន្លាស់ ចំនួន ២៤,៣% ស្មើនឹង ៧៥១ លានដុល្លារ ផលិតផលអេឡិចត្រូនិចកុំព្យូទ័រ និងគ្រឿងបន្លាស់របស់វាថយចុះ ១៧,១% ស្មើនឹង ៤២០ លានដុល្លារ ផលិតផលនេសាទថយចុះ ១៣,១% ស្មើនឹង ៦៦ លានដុល្លា។

ដោយឡែក ការនាំចូលបានកើនឡើង ១៤,៩% ធៀបទៅនឹងពាក់កណ្ដាលខែចុងក្រោយ នៃខែតុលា ឆ្នាំ២០២១ ដែលឆ្លុះបញ្ចាំងពីការកើនឡើង នៃការនាំចូលកុំព្យូទ័រ និងផលិតផលអេឡិចត្រូនិច គ្រឿងបន្លាស់ និងគ្រឿងបង្គុំមានចំនួន ១៧,២% ស្មើនឹង ៦៥១ លានដុល្លារ ម៉ាស៊ីន គ្រឿងបរិក្ខា និងឧបករណ៍មានចំនួន ១១,៩% ស្មើនឹង ២០៧ លានដុល្លារ និងប្រេងឆៅមានចំនួន ១២១,៥% ស្មើនឹង ១៨១ លានដុល្លារ៕ *ដោយ ជឹម ប៊ុនធឿន*

| | ទំហំជួញដូរ |
|---|---|
| ការនាំចូល | ១៤,៦១ |
| ការនាំចេញ | ១៤,៩៨ |
| តុល្យភាពពាណិជ្ជកម្ម | - ០,៣៧ |

*ប្រភព៖ Vietnam Customs*

## សេដ្ឋកិច្ចសកល

**អង្គការ OPEC+ ត្រូវបានរំពឹងថានឹងរក្សាការបង្កើនទិន្នផលប្រេងដែលបានគ្រោងទុក ខណៈមានការកើនឡើងនៃករណីឆ្លងវីរុសកូវីដ-១៩ បំប្លែងខ្លួនថ្មីអូមីក្រុង**

*ប្រភព៖ CNBC ២០២១, រូបភាព៖ Yegor Aleyev*

ក្រុមប្រទេសដ៏មានឥទ្ធិពលនៃប្រទេសផលិតប្រេង ហៅកាត់ថា OPEC+ នឹងជួបប្រជុំគ្នានៅថ្ងៃអង្គារ ទី០៤ ខែ



មករា ឆ្នាំ២០២២ តាមរយៈសន្និសីទវីដេអូ ដើម្បីពិភាក្សាអំពីដំណាក់កាលបន្ទាប់នៃការកំណត់គោលនយោបាយ

ផលិតប្រេង ខណៈដែលអ្នកវិនិយោគថាមពលថ្លឹងថ្លែងពីសក្តានុពលនៃផលប៉ះពាល់ពីការកើនឡើងករណីឆ្លងវីរុសកូវីដ-១៩ វ៉ារីយ៉ង់បំប្លែងខ្លួនថ្មីអូមីក្រុង។

ក្រុមអ្នកវិភាគថាមពល រំពឹងយ៉ាងមុតមាំថា OPEC+ នឹងប្រកាន់ខ្ជាប់នូវគោលនយោបាយក្នុងការបង្កើនទិន្នផលផលិតប្រេងចំនួន ៤០០ ០០០បារ៉ែលក្នុងមួយថ្ងៃ សម្រាប់ខែកុម្ភៈ ឆ្នាំ២០២២ ខាងមុខ ដូចដែលបានធ្វើជារៀងរាល់ខែចាប់ពីខែសីហា ឆ្នាំ២០២១ កន្លងមក ដោយសារសម្ពាធរបស់អាមេរិកក្នុងការជំរុញការផ្គត់ផ្គង់ និងមិនទាន់មានវិធានការរឹតត្បិតថ្មីទប់ស្កាត់ការរីករាលដាលនៃវីរុសកូវីដ-១៩ វ៉ារីយ៉ង់បំប្លែងខ្លួនថ្មីអូមីក្រុង។

តម្លៃប្រេងឆៅ Brent របស់អង់គ្លេស ត្រូវបានជួញដូរនៅតម្លៃ ៧៩,៦៣ដុល្លារអាមេរិកក្នុងមួយបារ៉ែល អំឡុងពេលកិច្ចព្រមព្រៀងនាពេលព្រឹកនៅទីក្រុងឡុងដ៍ ពោលគឺកើនឡើងប្រហែល ០,៨% ខណៈ តម្លៃប្រេងឆៅរបស់សហរដ្ឋអាមេរិក West Texas Intermediate (WTI) មានតម្លៃ ៧៦,៦៥ដុល្លារអាមេរិកក្នុងមួយបារ៉ែល កើនឡើងប្រហែល ០,៧៥%។ តម្លៃប្រេងនៅតែមានតម្លៃប្រហែល ៨០ដុល្លារអាមេរិកក្នុងមួយបារ៉ែល ដែលប្រហែលជាខ្ពស់ជាងអ្វីដែលលោកប្រធានាធិបតីអាមេរិក Joe Biden ចង់បាន នេះបើយោងតាមលោក Herman Wang និពន្ធនាយកនៃអង្គការ OPEC និងសារព័ត៌មានមជ្ឈិមបូព៌ានៅ S&P Global Platts។

តម្លៃប្រេងឆៅ បានកើនឡើងច្រើនជាង ៥០% កាលពីឆ្នាំ២០២១ ដោយសារអ្នកវិនិយោគថាមពលមានសុទិដ្ឋិនិយមថាការឆ្លងច្រើននៃវីរុសកូវីដ-១៩ បំប្លែងខ្លួនថ្មីអាចមិនសូវធ្ងន់ធ្ងរជាងការភ័យខ្លាចនោះទេ។

អ្នកវិភាគថាមពល ក៏រំពឹងផងដែរថាទីផ្សារថាមពលសកល នឹងនៅតែរងគ្រោះដោយសារជម្លោះភូមិសាស្ត្រនយោបាយនៅឆ្នាំ២០២២ ដោយមាន «ភាពរកាំរកូស» ជុំវិញការប្រឈមមុខដាក់គ្នារវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន និងកិច្ចចរចានុយក្លេអ៊ែរប្រទេសអ៊ីរ៉ង់ដែលកំពុងវិវត្តន៍ទៅមុខ ដែលនេះទំនងជាបញ្ហាដែលត្រូវបានតាមដានយ៉ាងដិតដល់ដោយ OPEC +។ *ដោយ ស៊ិន សុភាព*

*ប្រភព៖ CNBC ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២*

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបារាំង មើលឃើញកំណើនសេដ្ឋកិច្ចឆ្នាំ២០២១ ខ្ពស់ជាងការព្យាករណ៍ទុក

*ប្រភព៖ Reuters ២០២១, រូបភាព៖Gonzalo Fuentes*

សេដ្ឋកិច្ចរបស់ប្រទេសបារាំង នឹងកើនឡើងគួរឱ្យកត់សម្គាល់នៅឆ្នាំ២០២២ ជាមួយនឹងការព្យាករណ៍ថានឹងមានកំណើន ៤% ប៉ុន្តែសម្រាប់ឆ្នាំ២០២១ កំណើននឹងខ្ពស់ជាងការព្យាករណ៍បច្ចុប្បន្នរបស់រដ្ឋាភិបាល នៅក្នុង



អត្រា ៦,២៥% នេះបើយោងតាមប្រសាសន៍លោក Bruno Le Maire រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបារាំង។

លោក Le Maire បានបន្ថែមថា ទោះបីជាការកើនឡើងករណីឆ្លងនៃវីរុសកូវីដ-១៩ បំប្លែងថ្មីអូមីក្រុងកំពុងរំខានដល់វិស័យមួយចំនួន និងអាចមានការលំបាកខ្លះក្នុងខែមករា ឆ្នាំ២០២២ នេះក្តី ប៉ុន្តែគ្មានហានិភ័យដែលធ្វើឱ្យសេដ្ឋកិច្ចធ្លាក់ចុះនោះទេ។

លោក Le Maire បានបញ្ជាក់ថាការព្យាករណ៍នៃកំណើនសេដ្ឋកិច្ចនេះគឺនៅកម្រិតទាបជាងការព្យាករណ៍ជាផ្លូវការដោយធនាគារកណ្តាលបារាំង, IMF, និង

OECD ដែលព្យាករណ៍នឹងមានកំណើន ៦,៧%, ៦,៧៥% និង ៦,៨% រៀងៗគ្នា។ ជាមួយគ្នានេះ ប្រទេសបារាំងនឹងមានឱនភាពថវិកាទាបជាង ៨% នៃ ផ.ស.ស. នៅក្នុងឆ្នាំ២០២១ ខណៈដែលរដ្ឋាភិបាលបានរំពឹងថានឹងមានចំនួន ៨,២%៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ Reuters ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២*

## ចិនអាចជួបកង្វះខាតថាមពលម្តងទៀតដែរទេ ក្រោយឥណ្ឌូនេស៊ីផ្អាកការនាំចេញធ្យូងថ្មបណ្តោះអាសន្ន?



*ដោយ ខេមបូណូមីស(រូបតំណាង៖ ការផលិតធ្យូងថ្មក្នុងប្រទេសចិន )*

ប្រទេសឥណ្ឌូនេស៊ី ដែលជាប្រទេសនាំចេញធ្យូងថ្មដ៏ធំសម្រាប់ផលិតជាថាមពលអគ្គិសនីនោះ បានប្រកាសផ្អាកការនាំចេញធ្យូងថ្មសម្រាប់ខែមករាឆ្នាំ២០២២នេះទៅឱ្យប្រទេសចិន ដើម្បីធានាឱ្យបានការផ្គត់ផ្គង់នៅក្នុងស្រុក និងបញ្ចៀសការកាត់ផ្តាច់ចរន្តអគ្គិសនី។

ក្រុងប៉េកាំងបាន ពឹងផ្អែកខ្លាំងលើធ្យូងថ្មពីឥណ្ឌូនេស៊ីដើម្បីបំពេញតម្រូវការនៅក្នុងស្រុក។ ជាក់ស្តែង នៅ១១ខែដំបូងឆ្នាំ២០២១ ចិននាំចូលធ្យូងថ្ម ពីឥណ្ឌូនេស៊ីកើនឡើងជាង ៥៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ លើសពីនេះ ការនាំចូលធ្យូងថ្មពីឥណ្ឌូនេស៊ីតំណាងឱ្យជិត ៧៥% នៃការនាំចូលសរុបរបស់ប្រទេសចិន។

ទោះបីជាយ៉ាងណាក៏ដោយទីក្រុងប៉េកាំងអាចគ្រប់គ្រងស្ថានការណ៍នេះបាន ព្រោះបុណ្យចូលឆ្នាំចិន នាខែមករាខាងមុខ តម្រូវការថាមពល ពិសេសរោងចក្រ សហគ្រាស នឹងមិនមានច្រើនឡើយ។ ជាក់ស្តែង តម្រូវការថាមពលសម្រាប់រោងចក្រ ស្មើនឹងជាង៦០%នៃតម្រូវការសរុប។ ដូចនេះបុណ្យចូលឆ្នាំចិន នឹងជួយបន្ថយសម្ពាធកង្វះខាតធ្យូងថ្មរបស់ចិន ស្របពេលដែល ទីក្រុងហ្សាកាតា ផ្អាកនាំចេញតែសម្រាប់ខែមករាប៉ុណ្ណោះ។

កន្លងមកចិនធ្លាប់តែពឹងផ្អែកខ្លាំងលើធ្យូងថ្មរបស់អូស្ត្រាលី ប៉ុន្តែដោយសារជម្លោះរវាងភាគីទាំងពីរ ធ្វើឱ្យចិនបង្ខំចិត្តឈប់បញ្ជាទិញធ្យូងថ្ម ដែលធ្វើឱ្យប៉េកាំងខ្លួនឯងជួបប្រទះវិបត្តិខ្វះខាតថាមពល និងរុញច្រានឱ្យតំបន់សំខាន់ៗជាច្រើននៅទូទាំងប្រទេស មិនមានអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី០៥ខែមករា ឆ្នាំ២០២២។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១១ ខែមករា ឆ្នាំ២០២២

- អត្រានីកម្មភាពតាមរដូវកាលនៃតំបន់អឺរ៉ូ បានធ្លាក់ចុះដល់ 7.3%នៅក្នុងខែតុលា ឆ្នាំ 2021
- កំណើនអត្រាអតិផរណា នៅសហរដ្ឋអាមេរិកកើនឡើងដល់ 6% ក្នុងខែវិច្ឆិកា ឆ្នាំ 2021 ពី 5.7% នៅក្នុងខែតុលា

ថ្ងៃអង្គារ ទី១២ ខែមករា ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មរបស់អូស្ត្រាលីបាន ធ្លាក់ចុះក្នុងខែតុលា ឆ្នាំ 2021
- កំណើនអត្រាអតិផរណាប្រចាំឆ្នាំ នៅក្នុងប្រទេសប្រេស៊ីល ក្នុងខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃពុធ ទី១៣ ខែមករា ឆ្នាំ២០២២

- អត្រានីកម្មភាព តាមរដូវកាលនៅក្នុងប្រទេសកូរ៉េខាងត្បូងបានថយចុះ ក្នុងខែវិច្ឆិកា ឆ្នាំ 2021
- អត្រាអតិផរណាប្រចាំខែនៅសហរដ្ឋអាមេរិកបានចូលមកក្នុងកម្រិត 0.8% ក្នុងខែវិច្ឆិកា ឆ្នាំ

2021 ដែលខ្ពស់ជាងការព្យាករណ៍ទីផ្សារ 0.7% ហើយធៀបនឹង 0.9% ក្នុងខែមុន

ថ្ងៃព្រហស្បតិ៍ ទី១៤ ខែមករា ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មរបស់ចិនបានរួមតូច ក្នុងខែវិច្ឆិកា ឆ្នាំ 2021
- ការលក់រថយន្តនៅក្នុងប្រទេសចិនបានធ្លាក់ចុះ ក្នុងខែវិច្ឆិកា ឆ្នាំ 2021

ថ្ងៃសុក្រ ទី១៥ ខែមករា ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មនៅប្រទេសអាឡឺម៉ង់បានធ្លាក់ចុះយ៉ាងខ្លាំង ក្នុងខែតុលា ឆ្នាំ 2021
- ឱនភាពពាណិជ្ជកម្មរបស់ចក្រភពអង់គ្លេសបានរួមតូច ក្នុងខែតុលា ឆ្នាំ 2021៕